**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រ.ក/លេខ០១០.០៣៣/០៧ គជប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧

# កិច្ចប្រជុំរវាង គ.ជ.ប ជាមួយតំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល

នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០៧ គ.ជ.ប បានរៀបចំកិច្ចប្រជុំមួយជាមួយតំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ ២០០៧ ។ លទ្ធផលបណ្តោះអាសន្ននេះ គិតត្រឹមថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០០៧ មានអ្នកមកចុះឈ្មោះបោះឆ្នោតចំនួន ៣៧៨.៧៧៨ ស្មើនឹង ៥៥.៥០% នៃចំនួនប៉ាន់ស្មានអ្នកត្រូវចុះឈ្មោះបោះឆ្នោត ហើយស្មៀនឃុំ សង្កាត់ បានលុបឈ្មោះ ២០.១៧៨ នាក់ កែតម្រូវ ១២៥.៨១៦ នាក់ និងលុបឈ្មោះអ្នកបោះឆ្នោតចេញពីទម្រង់ ១០២៥ ដែលជាបញ្ជីឈ្មោះត្រៀមលុបចេញពីបញ្ជីបោះឆ្នោតចំនួន ២៣.១៥២ នាក់ ។

ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក គ.ជ.ប បានមានប្រសាសន៍ថា ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា រហូតដល់ពេលនេះ ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅអស់រយៈពេលជិតបីសប្តាហ៍ហើយៗនៅសល់ពេលជាងពីរសប្តាហ៍ទៀតនឹងបញ្ចប់ដំណើរការនេះ ។ ឯកឧត្តមបានបន្ថែមថា តាមសំណើរបស់ គ.ជ.ប ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំជំរុញឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ផ្តល់អាទិភាពដល់ការអនុវត្តការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមប្រតិទិនកំណត់របស់ គ.ជ.ប ។

ទាក់ទងនឹងដំណើរការនេះដែរ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានធ្វើការប្រៀបធៀបចំនួនអ្នកទៅចុះឈ្មោះបោះឆ្នោត សម្រាប់ឆ្នាំនេះ គឺតិចជាងឆ្នាំ ២០០៦ បើប្រៀបធៀបទៅនឹងពេលវេលាដូចគ្នា។ ឯកឧត្តមបានបញ្ជាក់ថា គ.ជ.ប កំពុងជំរុញការផ្សព្វផ្សាយថែមទៀត ដើម្បីឱ្យប្រជាពលរដ្ឋដែលមានអាយុ ១៨ ឆ្នាំឡើងបានទៅចុះឈ្មោះបោះឆ្នោតគ្រប់ៗគ្នា ។

ជាមួយគ្នានេះ នៅក្នុងកិច្ចប្រជុំនោះ តំណាងអង្គការមិនមែនរដ្ឋាភិបាល បានលើកសរសើរពីការខិតខំប្រឹងប្រែងរបស់ គ.ជ.ប ដែលជួយជំរុញដល់អាជ្ញាធរ ដើម្បីឱ្យប្រជាពលរដ្ឋមួយចំនួនដូចជា អ្នកផ្លាស់ចេញពីសហគមន៍សំបុកចាបក្រុងភ្នំពេញ និងឃុំត្រពាំងភ្លាំង ខេត្តកំពត បានចុះឈ្មោះបោះឆ្នោត ។ តំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន ក៏បានលើកជាសំនួរថា ÷

- អ្នកទៅពិនិត្យបញ្ជីឈ្មោះមានចំនួនតិច មូលហេតុអ្វី ?
- មានក្រុមហ៊ុនមួយនៅប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជំរុញឱ្យបុគ្គលិកចុះឈ្មោះបោះឆ្នោតហើយបើបុគ្គលិកមិនចុះឈ្មោះបោះឆ្នោត ក្រុមហ៊ុនមិនឱ្យស្នាក់នៅទីកន្លែងរបស់ក្រុមហ៊ុន តើ គ.ជ.ប គិតមានវិធានការយ៉ាងណា ?
- មានការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចាប់ពីអាយុ ១៥ ឆ្នាំ តើ គ.ជ.ប គិតយ៉ាងណា ?

ពាក់ព័ន្ធនឹងការលើកឡើងខាងលើ ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប បានពន្យល់ថា គ្រួសារខ្លះមានតំណាងទៅពិនិត្យមើលឈ្មោះហើយប្រជាពលរដ្ឋខ្លះគាត់អាចសាកសួរព័ត៌មានដោយផ្ទាល់ពីស្មៀន ឬពីក្រុមប្រឹក្សាឃុំ សង្កាត់ ។ ម្យ៉ាងទៀតច្បាប់បោះឆ្នោតមិនបានបង្ខំឱ្យគាត់ត្រូវតែទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនោះទេ ។ ឯកឧត្តម បានបន្ថែមថា គ.ជ.ប បានបិទផ្សាយទម្រង់ ១០២៥ ចំនួនពីរលើករួចមកហើយ គឺលើកទី ១ នៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៧ និង លើកទី ២ នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៧ នៅសាលាឃុំ សង្កាត់ និងបានបិទផ្សាយនៅគ្រប់ភូមិទៀត ។ បន្ថែមលើនេះ គ.ជ.ប បានផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន បដា ខិត្តប័ណ្ណ ដើម្បីអញ្ជើញពួកគាត់ទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

ចំពោះករណីនៅឃុំប៉ោយប៉ែត ឯកឧត្តមបានមានប្រសាសន៍ថា គ.ជ.ប បានចាត់ឱ្យលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តបន្ទាយមានជ័យ ធ្វើការស្រាវជ្រាវហើយ ។

ដោយឡែកការធ្វើអត្តសញ្ញាណប័ណ្ណ ឯកឧត្តមបានបញ្ជាក់ថា ជាសេចក្តីណែនាំថ្មីរបស់រាជរដ្ឋាភិបាល ហើយវាជាការប្រសើរដែលប្រជាពលរដ្ឋខ្មែរ មានអត្តសញ្ញាណប័ណ្ណតាំងពីអាយុ ១៥ ឆ្នាំ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកគាត់មិនអាចចុះឈ្មោះបោះឆ្នោតបានដែរ ព្រោះពួកគាត់មិនទាន់គ្រប់អាយុបោះឆ្នោត ។